ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អល.មផ 806C3E26

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
នាយកដ្ឋានកិច្ចការរដ្ឋបាល

ប្រញាប់ណាស់

**កំណត់បង្ហាញលិខិតចូល**

**ក្រសួង-ស្ថាប័ន** ៖ ក្រសួងយុត្តិធម៌ លេខ ០៣៥៩ កយ.រប/២៦ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦

**កម្មវត្ថុ** ៖ សំណើសូមចាត់ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជាអនុប្រធានអចិន្ត្រៃយ៍ នៃ គ.ជ.ប.ជ និង**លោកជំទាវឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ ចូលរួមកិច្ចប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា" និងសេចក្តីព្រាងច្បាប់ស្តីពី "ការបង្ក្រាបអំពើរត់ពន្ធមនុស្ស"។

**ខ្លឹមសារសង្ខេប** ៖ កិច្ចប្រជុំខាងលើ នឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង ២:៣០នាទីរសៀល នៅទីស្តីការក្រសួងយុត្តិធម៌**។

**យោបល់ ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី**

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦

គឹម ជេងហ្វៃ

**យោបល់ នាយកដ្ឋាន**
**គោរពជូន ឯកឧត្តម អគ្គលេខាធិការ**

- គួរគោរពជូន **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី** ដើម្បីពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។
- គួរគោរពជូន លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងលោកជំទាវឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីអញ្ជើញចូលរួម។

ដោយសេចក្តីគោរព!

ណា ស្រស់បញ្ញារ៉ា

**យោបល់ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**យោបល់ ឯកឧត្តម អគ្គលេខាធិការ**

- សូមគោរពជូន **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី** ដើម្បីពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។
- គួរគោរពជូន លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងលោកជំទាវឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីអញ្ជើញចូលរួម។

ដោយសេចក្តីគោរព!

09.02.26.

ឧត្តមសេនីយ៍ឯក.ជា_សុធន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

អល.មផ 806C3E26

លេខ [illegible]/២៦

អគ្គលេខាធិការដ្ឋាន

ចូល លេខ 226 15:05 ថ្ងៃ 06-01-26 បញ្ជូន

ថ្ងៃ សុក្រ ៤ រោច ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៦

**សូមគោរពជូន**

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

**កម្មវត្ថុ ៖** សំណើសូមចាត់លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃ **គ.ជ.ប.ជ.** និងលោកជំទាវឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ជ.** ចូលរួមកិច្ចប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**" និងសេចក្តីព្រាងច្បាប់ស្តីពី "**ការបង្ក្រាបអំពើរត់ពន្ធមនុស្ស**"។

**យោង ៖** ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា បន្ទាប់ពីទទួលបានគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**, ក្រសួងយុត្តិធម៌បានសិក្សា និងរៀបចំរួចរាល់នូវសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**" និងបានពិនិត្យ និងកែសម្រួលរួចរាល់នូវសេចក្តីព្រាងច្បាប់ស្តីពី "**ការបង្ក្រាបអំពើរត់ពន្ធមនុស្ស**" ផងដែរ។ យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**, ក្រសួងយុត្តិធម៌នឹងរៀបចំកិច្ចប្រជុំអន្តរក្រសួងចង្អៀតមួយដើម្បីពិនិត្យពិភាក្សា និងពិគ្រោះយោបល់ដើម្បីប្រមូលធាតុចូលបន្ថែមលើសេចក្តីព្រាងច្បាប់ទាំង ២ នេះ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង ២:៣០ នាទីរសៀល នៅទីស្តីការក្រសួងយុត្តិធម៌។ ខ្ញុំនឹងដឹកនាំកិច្ចប្រជុំនេះដោយផ្ទាល់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងចាត់លោកជំទាវ **ជូ ប៊ុនអេង** និងលោកជំទាវឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** ដើម្បីចូលរួមកិច្ចប្រជុំនេះតាមការគួរ។

សូម **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ.** មេត្តាទទួលនូវគារវកិច្ចដ៏ជ្រាលជ្រៅពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**សូមបញ្ជាក់ពីការចូលរួម៖**

- លោកស្រី ហ៊ិន សុភាព - ០១២ ៩៨៩ ១៥៥
- លោក កែវ ឧត្តម - ០៩២ ៩៦៩ ៦៧៨

មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ ៖ 023 216 322, 023 217 841, 023 212 693

# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-** គោលបំណង

ច្បាប់នេះកំណត់អំពីវិធានផ្នែកព្រហ្មទណ្ឌដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សំដៅចូលរួមថែរក្សាការពារសន្តិសុខសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។

**មាត្រា២ .-** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបទល្មើសឆបោកដែលត្រូវបានប្រព្រឹត្តតាមប្រព័ន្ធបច្ចេកវិទ្យា ឬដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយដើម្បីប្រព្រឹត្តបទល្មើស ព្រមទាំងចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

បទល្មើសដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់នេះ គឺជាបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងករណីណាមួយដូចខាងក្រោម៖

១-បទល្មើសត្រូវបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន។

២-បទល្មើសត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីណាមួយដូចខាងក្រោម៖

- បទល្មើសត្រូវបានប្រព្រឹត្តដោយពលរដ្ឋខ្មែរ។
- បទល្មើសត្រូវបានប្រព្រឹត្តលើពលរដ្ឋខ្មែរ។
- ទ្រព្យសម្បត្តិដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស ឬផលនៃបទល្មើសដែលមានចែងក្នុងច្បាប់នេះ បានផ្ទេរមកក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-បទល្មើសត្រូវបានប្រព្រឹត្តដោយប្រើប្រព័ន្ធធនាគារ ឬប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៣ .-** យន្តការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

ការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាគឺជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចបង្កើតយន្តការដោយឡែកក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងអនុវត្តការងារបង្ការ ទប់ស្កាត់ និងប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសដែលមានចែងក្នុងច្បាប់នេះ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។

ការសម្របសម្រួលសមត្ថកិច្ចរវាងមន្ត្រីនគរបាលយុត្តិធម៌ និងយន្តការនេះ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា៤** .- ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីរាជការទទួលបន្ទុកការងារបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលបម្រើការងារក្នុងយន្តការដែលត្រូវបានបង្កើតឡើងតាមមាត្រា៣ (យន្តការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) នៃច្បាប់នេះ អាចទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីពិនិត្យ ស៊ើបអង្កេត និងស្រាវជ្រាវបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ។ ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីរាជការបម្រើការងារក្នុងយន្តការនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការធ្វើសម្បថ និងការអនុវត្តការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៣
## បទល្មើសទាក់ទងនឹងអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

**មាត្រា៥** .- បទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឧបាយកលទុច្ចរិត ដែលត្រូវបានប្រព្រឹត្តតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ឬដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយ ក្នុងគោលបំណងទទួលបាននូវ៖

១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

២-ការផ្តត់ផ្គង់សេវា។

៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល។

អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្ត៖

១-ដោយមានការរៀបចំជាក្រុមមានការចាត់តាំង ឬដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត។

២-ដោយមានជនរងគ្រោះច្រើននាក់។

**មាត្រា៦** .- បទរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

អំពើរៀបចំ ឬដឹកនាំទីកន្លែងឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលមានលក្ខណៈប្រមូលផ្តុំ ឬក្នុងទម្រង់ជាមជ្ឈមណ្ឌល ដែលអនុញ្ញាតឱ្យបុគ្គលច្រើននាក់ចងក្រងគ្នាជាក្រុម ឬជាបណ្តាញ ទោះមាន ឬគ្មានរចនាសម្ព័ន្ធគ្រប់គ្រងជាក់លាក់ក៏ដោយ ដើម្បីប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវកំណត់ជាបទល្មើសរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល។

ត្រូវចាត់ទុកថាជាបទល្មើសរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងត្រូវផ្ដន្ទាទោសដូចគ្នានឹងបទល្មើសដែលមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះផងដែរ ចំពោះអំពើរៀបចំ ឬដឹកនាំទីកន្លែងដាច់ដោយឡែកៗពីគ្នាដើម្បីប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ប៉ុន្តែអាចចងក្រងគ្នាជាបណ្ដាញតាមគ្រប់រូបភាព ទោះបីពុំមានលក្ខណៈប្រមូលផ្ដុំគ្នាក្នុងទម្រង់ជាមជ្ឈមណ្ឌលក៏ដោយ។

អំពើរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ទៅ ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ

១-ដោយប្រើអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

២-ដោយមានការចាប់ ការឃុំឃាំង ឬការបង្ខាំង។

៣-ដោយមានការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស ការកេងចំណេញលើពលកម្ម ការធ្វើអំពើបង្ខិតបង្ខំឱ្យធ្វើសកម្មភាពខុសពីឆន្ទៈ ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត។

អំពើរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយបណ្ដាលឱ្យមានមនុស្សស្លាប់ម្នាក់ ឬច្រើននាក់។

**មាត្រា៧ .. បទជ្រើសរើស ឬបណ្ដុះបណ្ដាលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**

អំពើជ្រើសរើស ឬបណ្ដុះបណ្ដាលអ្នកដទៃក្នុងគោលបំណងឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល។

អំពើជ្រើសរើស ឬបណ្ដុះបណ្ដាលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ

១-ដោយប្រើអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

២-ដោយមានការចាប់ ការឃុំឃាំង ឬការបង្ខាំង។

៣-ដោយបណ្ដាលឱ្យមានមនុស្សស្លាប់។

៤-ដោយដឹងថាបុគ្គលដែលត្រូវបានជ្រើសរើស ឬបណ្ដុះបណ្ដាល គឺជាជនរងគ្រោះនៃអំពើរត់ពន្ធមនុស្ស ឬអំពើជួញដូរមនុស្ស។

**មាត្រា៨ .. បទប្រមូលក្នុងចេតនាទុច្ចរិតនូវឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ ៣០០ ០០០ ០០០ (បីរយលាន) រៀល ចំពោះបុគ្គលដែលប្រមូលនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ ក្នុងគោលបំណងប្រើប្រាស់ ឬបង្កើតជាអាទិ៍នូវគណនីធនាគារ គណនីអនឡាញ វេបសាយ គណនីអេឡិចត្រូនិក ឬគណនីបណ្ដាញសង្គមនានា សម្រាប់ជាមធ្យោបាយប្រព្រឹត្តបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

អំពើប្រមូលក្នុងចេតនាទុច្ចរិតនូវឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០០ ០០០ ០០០ (បីរយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយក្រុមមានការចាត់តាំង។

**មាត្រា៩ .. បទសម្អាតប្រាក់ពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងច្បាប់នេះ**

ត្រូវចាត់ទុកថាជាទម្រង់មួយនៃបទល្មើសសម្អាតប្រាក់ និងត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសសម្អាតប្រាក់ ក្នុងករណីដែលម្ចាស់ទ្រព្យមិនមានភស្តុតាងបង្ហាញអំពីប្រភពស្របច្បាប់ ដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស ឬជាផលនៃបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬបទល្មើសពាក់ព័ន្ធផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា១០ .. ទោសបន្ថែម**

ចំពោះជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងចាប់ពីមាត្រា៥ (បទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) ដល់មាត្រា៨ (បទប្រមូលក្នុងចេតនាទុច្ចរិតនូវឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ) នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។

តុលាការអាចប្រកាសរឹបអូសជាទ្រព្យសម្បត្តិរដ្ឋនូវអចលនវត្ថុដែលត្រូវបានប្រើប្រាស់ជាទីតាំង ឬមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

តុលាការអាចសម្រេចបិទ ឬលុបគណនីធនាគារ គណនីអនឡាញ វេបសាយ គណនីអេឡិចត្រូនិក ឬគណនីបណ្តាញសង្គមនានា ដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយប្រព្រឹត្តបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងដែលត្រូវបានបង្កើតឡើងដោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា១១ .. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៥ (បទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) ដល់មាត្រា៩ (បទសម្អាតប្រាក់ពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងច្បាប់នេះ) នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ទៅ ៣០ ០០០ ០០០ ០០០ (សាមសិបពាន់លាន) រៀល ឬរហូតដល់ស្មើនឹងតម្លៃមូលនិធិ ឬទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា១២ .. ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដូចមានចែងក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ។

**មាត្រា១៣ .- ការប្រកាសមូលទោស**

បទប្បញ្ញត្តិនៃមាត្រា៩៧ (ការប្រកាសមូលទោស) នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ។ ការប្រកាសមូលទោសត្រូវអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មូលទោសចំពោះបទល្មើសទាំងឡាយដូចមានចែងក្នុងច្បាប់នេះ មិនអាចត្រូវបានជំនួសដោយទោសជំនួស ឬទោសបន្ថែមតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឡើយ។

**មាត្រា១៤ .- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនដែលត្រូវបានបង្ខំឱ្យធ្វើសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**

ជនដែលបានចូលរួមប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ មិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះឡើយ ដោយអនុវត្តស្របតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន។

**មាត្រា១៥ .- ការលើកលែងឱ្យរួចផុតពីទោស និងស្ថានសម្រាលទោស**

បុគ្គលណាដែលបានចូលរួមប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងមាត្រា៦ (បទរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) និងមាត្រា៧ (បទជ្រើសរើស ឬបណ្ដុះបណ្ដាលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) នៃច្បាប់នេះ ត្រូវលើកលែងឱ្យរួចផុតពីការទទួលទោស ប្រសិនបើមុនការចោទប្រកាន់ បុគ្គលនោះបានបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ចអំពីអត្ថិភាពនៃអំពើនេះ ហើយបាននាំឱ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត ឬអាចនាំឱ្យប្រមូលមកវិញបាននូវផលនៃបទល្មើស។

ប៉ុន្តែ បុគ្គលនោះត្រូវទទួលបាននូវស្ថានសម្រាលទោស ប្រសិនបើការបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ចខាងលើ ធ្វើឡើងក្រោយការចោទប្រកាន់។ អានុភាពនៃស្ថានសម្រាលទោសនេះ ត្រូវអនុវត្តស្របតាមក្រមព្រហ្មទណ្ឌ។

## ជំពូកទី៤
## បទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ

**មាត្រា១៦ .- នីតិវិធីនៃការអនុវត្ត**

នីតិវិធីសម្រាប់អនុវត្តចំពោះការពិនិត្យ ការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ការផ្ដន្ទាទោសចំពោះបទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសពាក់ព័ន្ធផ្សេងទៀតដូចមានចែងក្នុងច្បាប់នេះ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់នេះ។

**មាត្រា១៧ .- ការឃាត់ខ្លួន**

ការឃាត់ខ្លួនត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ផ្អែកតាមតម្រូវការចាំបាច់នៃការអនុវត្តនីតិវិធី រយៈពេលនៃការឃាត់ខ្លួនអាចពន្យារពេលរៀងរាល់ ៤៨ (សែសិបប្រាំបី) ម៉ោងម្ដង ដោយមានការអនុញ្ញាតពីព្រះរាជអាជ្ញា ក្នុងករណីដូចតទៅ៖

- បទល្មើសត្រូវបានប្រព្រឹត្តដោយក្រុមមានការចាត់តាំង ឬដោយមានជនសង្ស័យច្រើននាក់។
- បទល្មើសត្រូវបានប្រព្រឹត្តដោយមានជនរងគ្រោះច្រើននាក់។

រយៈពេលសរុបនៃការឃាត់ខ្លួនមិនត្រូវលើសពី ១០ (ដប់) ថ្ងៃ។

ការពន្យារពេលនៃការឃាត់ខ្លួនគឺជាវិធានការពិសេស។ រាល់ការពន្យារពេលនៃការឃាត់ខ្លួនត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញា ដែលត្រូវផ្ទៀតផ្ទាត់មើលមូលកភាពឱ្យបានច្បាស់លាស់ និងយោងលើតម្រូវការចាំបាច់ក្នុងការអនុវត្តនីតិវិធី។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវកត់ត្រាចូលក្នុងកំណត់ហេតុឃាត់ខ្លួនអំពីការសម្រេចរបស់ព្រះរាជអាជ្ញាដែលអនុញ្ញាតឱ្យពន្យារពេលនៃការឃាត់ខ្លួន។

## មាត្រា១៨ .- ការផ្អាក ការឃាត់ទុក និងការបង្កក

ក្នុងករណីដែលពិនិត្យឃើញមានប្រតិបត្តិការសង្ស័យ ឬដើម្បីទប់ស្កាត់ការផ្ទេរចេញនូវសាច់ប្រាក់ពីគណនីដែលសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើស ឬផលនៃបទល្មើសដែលមានកំណត់ក្នុងច្បាប់នេះ មន្ត្រីនគរបាលយុត្តិធម៌ អាចស្នើសុំដោយផ្ទាល់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឱ្យផ្អាកជាបណ្តោះអាសន្ននូវប្រតិបត្តិការសង្ស័យ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវធ្វើការផ្អាកប្រតិបត្តិការនោះភ្លាមៗដោយគ្មានបង្អង់។ ការផ្អាកប្រតិបត្តិការសង្ស័យ មានរយៈពេលមិនលើសពី ៤៨ (សែសិបប្រាំបី) ម៉ោង។ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីសម្រេចអំពីការឃាត់ទុកគណនី ឬស្នើសុំទៅតុលាការដើម្បីសម្រេចបង្កកគណនីនោះ។ តុលាការអាចសម្រេចអំពីការឃាត់ទុក និងការបង្កកគណនីនេះដោយឯកឯងបាន។

ក្នុងករណីដែលពិនិត្យឃើញមានទ្រព្យសម្បត្តិ ឬប្រតិបត្តិការសង្ស័យផ្សេងទៀតជាប់ពាក់ព័ន្ធបទល្មើស ឬផលនៃបទល្មើសដែលមានកំណត់ក្នុងច្បាប់នេះ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីឃាត់ទុកទ្រព្យសម្បត្តិ ឬផ្អាកប្រតិបត្តិការទាំងនោះជាបណ្តោះអាសន្ន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការជាបន្ទាន់ដើម្បីឃាត់ទុកទ្រព្យសម្បត្តិ ឬផ្អាកប្រតិបត្តិការទាំងនោះជាបណ្តោះអាសន្ន។

តុលាការត្រូវសម្រេចអំពីការឃាត់ទុក ឬការបង្កកគណនី ឬទ្រព្យសម្បត្តិនេះ ក្នុងរយៈពេលមិនលើសពី ៤៨ (សែសិបប្រាំបី) ម៉ោង គិតពីថ្ងៃទទួលពាក្យស្នើសុំ ឬពាក្យបណ្តឹង។ រយៈពេលនេះអាចពន្យារពេលបានមិនលើសពី ២៤ (ម្ភៃបួន) ម៉ោង ចំពោះបទល្មើសដែលមានលក្ខណៈស្មុគស្មាញ។

ម្ចាស់គណនី ម្ចាស់ទ្រព្យសម្បត្តិ ឬតតិយជនដែលមានប្រយោជន៍ពាក់ព័ន្ធ អាចប្តឹងតវ៉ាចំពោះការសម្រេចរបស់តុលាការដូចមានកំណត់ក្នុងកថាខណ្ឌខាងលើនេះ បន្ទាប់ពីបានទទួលដំណឹងអំពីវិធានការបណ្តោះអាសន្ននេះ ដោយអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

## មាត្រា១៩ .- ការសម្ងាត់វិជ្ជាជីវៈ

ការសម្ងាត់វិជ្ជាជីវៈ ពុំមែនជាឧបសគ្គរាំងដល់ការអនុវត្តច្បាប់នេះឡើយ។

## មាត្រា២០ .- កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការជាមួយរដ្ឋបរទេសទាក់ទងនឹងបត្យាប័ន និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ជាអាទិ៍ ការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើស រួមទាំងការប្រមូល និងចែករំលែកព័ត៌មាន ការកំណត់អត្តសញ្ញាណបុគ្គល ការកំណត់អត្តសញ្ញាណទ្រព្យ ការឃាត់ទុកឬបង្កកទ្រព្យ និងការប្រមូលត្រឡប់មកវិញនូវផលនៃបទល្មើសពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវអនុវត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ដែលកម្ពុជាជារដ្ឋភាគី។

**មាត្រា២១ .- ការរឹបអូសទ្រព្យសម្បត្តិ**

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំតាមដីកាបញ្ជូនទៅតុលាការព្រហ្មទណ្ឌឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិដែលជាមធ្យោបាយប្រព្រឹត្តបទល្មើស ទីតាំងប្រព្រឹត្តបទល្មើស ឬផលនៃបទល្មើសដូចមានចែងក្នុងច្បាប់នេះ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា២២ .- ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**

ក្រៅពីបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ បទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវិធានការប្រឆាំងការសម្អាតប្រាក់ដែលពាក់ព័ន្ធនឹងបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៣ .- ការប្រកាសឱ្យប្រើ និងការអនុវត្តច្បាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះមានអានុភាពអនុវត្តភ្លាម។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា<br>
អនុម័តនៅថ្ងៃទី.........ខែ..........ឆ្នាំ..........<br>
នាសម័យប្រជុំរដ្ឋសភាលើកទី............. នីតិកាលទី៧។<br>
ថ្ងៃ...............ខែ...........ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩<br>
រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ............

**ប្រធានរដ្ឋសភា**

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី**

# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ការបង្ក្រាបអំពើរត់ពន្ធមនុស្ស

ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១** .. គោលបំណង

ច្បាប់នេះកំណត់អំពីវិធានផ្នែកព្រហ្មទណ្ឌដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការរត់ពន្ធមនុស្ស សំដៅចូលរួមថែរក្សាការពារសន្តិសុខសាធារណៈនិងសណ្តាប់ធ្នាប់សង្គម និងការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងពិធីសារពាក់ព័ន្ធ ក៏ដូចជាកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។

**មាត្រា២** .. វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបទល្មើសរត់ពន្ធមនុស្ស ព្រមទាំងចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការរត់ពន្ធមនុស្ស។

បទល្មើសដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់នេះ គឺជាបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងករណីណាមួយដូចខាងក្រោម៖

១-បទល្មើសត្រូវបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន។

២-បទល្មើសត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ឬលើពលរដ្ឋខ្មែរ។

## ជំពូកទី២
## បទល្មើសទាក់ទងនឹងអំពើរត់ពន្ធមនុស្ស

**មាត្រា៣** .. បទរត់ពន្ធមនុស្ស

អំពើរត់ពន្ធមនុស្ស គឺជាអំពើរៀបចំ ឬសម្រួលឱ្យចូល ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់នូវជនបរទេសណាម្នាក់ ឬឱ្យចេញពីព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ទៅរដ្ឋបរទេសណាមួយនូវជនណាម្នាក់ ក្នុងគោលបំណងទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្សេងទៀត ទោះដោយផ្ទាល់ ឬដោយប្រយោល។

អំពើរត់ពន្ធមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល។

ត្រូវចាត់ទុកថាជាបទល្មើសរត់ពន្ធមនុស្ស និងត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសដែលមានកំណត់ក្នុងកថាខណ្ឌខាងលើផងដែរ ចំពោះអំពើរៀបចំ ឬសម្រួលឱ្យចេញ ចូល ឬឆ្លងកាត់រដ្ឋបរទេសដោយខុសច្បាប់នូវជនដែលគ្មានសញ្ជាតិនៃរដ្ឋបរទេសនោះ ឬជនដែលគ្មានសិទ្ធិរស់នៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋបរទេសនោះ។

អំពើរត់ពន្ធមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ

១-ដោយក្រុមមានការចាត់តាំង។

២-ដោយមានជនត្រូវបានគេរត់ពន្ធលើសពី ៥ (ប្រាំ) នាក់។

៣-ដោយមានជនត្រូវបានគេរត់ពន្ធជាអនីតិជន។

៤-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

អំពើរត់ពន្ធមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើជនល្មើសបានដឹង ឬអាចដឹងថាក្នុងពេលកំពុងធ្វើដំណើរ ឬពេលទៅដល់រដ្ឋណាមួយ ជនត្រូវបានគេរត់ពន្ធស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោមៈ

១-ជនរងគ្រោះត្រូវបានគេរត់ពន្ធដើម្បីបម្រើឱ្យគោលដៅនៃការប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬបទឧក្រិដ្ឋឬបទមជ្ឈិមផ្សេងទៀត។

២-ទទួលរងអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

៣-ទទួលរងអំពើទាសភាព ពលកម្មដោយបង្ខំ អាជីវកម្មផ្លូវភេទ ឬការកាត់យកសរីរាង្គ។

៤-ទទួលរងរបួសធ្ងន់ធ្ងរ ឬអាចមានគ្រោះថ្នាក់ដល់ស្លាប់។

អំពើរត់ពន្ធមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយបណ្តាលឱ្យជនត្រូវបានគេរត់ពន្ធម្នាក់ ឬច្រើននាក់ស្លាប់។

## មាត្រា៤.- បទដឹកជញ្ជូនឆ្លងដែនដោយខុសច្បាប់

អំពើដឹកជញ្ជូនឆ្លងដែនដោយខុសច្បាប់ គឺជាការដឹកជញ្ជូនចេញ ចូល ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជានូវជនត្រូវបានគេរត់ពន្ធ ឬជនណាម្នាក់ដោយដឹងថាជននោះពុំមានឯកសារទាំងឡាយដែលចាំបាច់សម្រាប់ការចេញ ឬចូលព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ក្នុងគោលបំណងទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្សេងទៀត ទោះដោយផ្ទាល់ ឬដោយប្រយោល។

អំពើដឹកជញ្ជូនឆ្លងដែនដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល។

អំពើដឹកជញ្ជូនឆ្លងដែនដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ

១-ដោយក្រុមមានការចាត់តាំង។

២-ដោយមានជនត្រូវបានគេរត់ពន្ធ ឬជនឆ្លងដែនខុសច្បាប់ លើសពី ៥ (ប្រាំ) នាក់។

៣-ដោយមានជនត្រូវបានគេរត់ពន្ធ ឬជនឆ្លងដែនខុសច្បាប់ ជាអនីតិជន។

៤-ដោយជនល្មើសបានដឹង ឬអាចដឹងថាជនរងគ្រោះត្រូវបានគេរត់ពន្ធដើម្បីបម្រើឱ្យគោលដៅនៃការប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬបទឧក្រិដ្ឋឬបទមជ្ឈិមផ្សេងទៀត។

៥-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

អំពើដឹកជញ្ជូនឆ្លងដែនដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើជនល្មើសបានដឹង ឬអាចដឹងថាក្នុងពេលកំពុងធ្វើដំណើរ ឬពេលទៅដល់រដ្ឋណាមួយ ជនត្រូវបានគេរត់ពន្ធ ឬជនឆ្លងដែនខុសច្បាប់ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

១-ទទួលរងអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

២-ទទួលរងអំពើទាសភាព ពលកម្មដោយបង្ខំ អាជីវកម្មផ្លូវភេទ ឬការកាត់យកសរីរាង្គ។

៣-ទទួលរងរបួសធ្ងន់ធ្ងរ ឬអាចមានគ្រោះថ្នាក់ដល់ស្លាប់។

អំពើដឹកជញ្ជូនឆ្លងដែនដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយបណ្តាលឱ្យជនត្រូវបានគេរត់ពន្ធ ឬជនឆ្លងដែនខុសច្បាប់ ម្នាក់ ឬច្រើននាក់ស្លាប់។

មិនត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះទេ ក្នុងករណីដែលអ្នកដឹកជញ្ជូនពាណិជ្ជកម្ម ស្ថិតក្នុងកាលៈទេសៈណាមួយដូចខាងក្រោម៖

១-មានមូលហេតុសមហេតុផលក្នុងការជឿថា ឯកសារទាំងឡាយរបស់អ្នកដំណើរគឺជាឯកសារធ្វើដំណើរចាំបាច់សម្រាប់ការចូលក្នុងប្រទេសណាមួយដោយស្របច្បាប់។

២-មានមូលហេតុសមហេតុផលក្នុងការជឿថា អ្នកដំណើរបានបង្ហាញឯកសារអត្តសញ្ញាណ និងឯកសារធ្វើដំណើរស្របច្បាប់ដើម្បីចូលទៅក្នុងប្រទេសណាមួយនៅពេលឡើងលើយានជំនិះដើម្បីធ្វើដំណើរទៅកាន់ប្រទេសនោះ។

៣-មានមូលហេតុដោយសារការជួយសង្គ្រោះមនុស្ស។

៤-ក្នុងកាលៈទេសៈណាមួយដែលហួសពីការគ្រប់គ្រងរបស់អ្នកដឹកជញ្ជូន។

៥-អ្នកដំណើរឆ្លងដែនដោយខុសច្បាប់ទទួលបានការការពារប្រឆាំងនឹងការបញ្ជូនត្រឡប់ ឬសិទ្ធិជ្រកកោននៅក្នុងប្រទេសណាមួយនៅពេលទៅដល់ប្រទេសនោះ។

**មាត្រា៥ _ បទផ្តល់ការស្នាក់នៅដោយខុសច្បាប់**

អំពើផ្តល់ការស្នាក់នៅដោយខុសច្បាប់ គឺជាការផ្តល់ជម្រក ឬទទួលឱ្យស្នាក់នៅដោយខុសច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា នូវជនណាម្នាក់ដោយដឹងថាជននោះជាជនត្រូវបានគេរត់ពន្ធ ក្នុងគោលបំណងទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្សេងទៀត ទោះដោយផ្ទាល់ ឬដោយប្រយោល។

អំពើផ្តល់ការស្នាក់នៅដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល។

អំពើផ្តល់ការស្នាក់នៅដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្ត៖

១-ដោយក្រុមមានការចាត់តាំង។

២-ដោយមានជនត្រូវបានគេរត់ពន្ធលើសពី ៥ (ប្រាំ) នាក់។

៣-ដោយមានជនត្រូវបានគេរត់ពន្ធ ជាអនីតិជន។

៤-ដោយជនល្មើសបានដឹង ឬអាចដឹងថាជនរងគ្រោះត្រូវបានគេជួញដូរដើម្បីបម្រើឱ្យគោលដៅនៃការប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬបទឧក្រិដ្ឋឬបទមជ្ឈិមផ្សេងទៀត។

៥-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

អំពើផ្តល់ការស្នាក់នៅដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើជនល្មើសបានដឹង ឬអាចដឹងថាជនត្រូវបានគេជួញដូរស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

១-ទទួលរងអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

២-ទទួលរងអំពើទាសភាព ពលកម្មដោយបង្ខំ អាជីវកម្មផ្លូវភេទ ឬការកាត់យកសរីរាង្គ។

៣-ទទួលរងរបួសធ្ងន់ធ្ងរ ឬអាចមានគ្រោះថ្នាក់ដល់ស្លាប់។

អំពើផ្តល់ការស្នាក់នៅដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយបណ្តាលឱ្យជនត្រូវបានគេជួញដូរម្នាក់ ឬច្រើននាក់ស្លាប់។

**មាត្រា៦** .. ទោសបន្ថែម

ចំពោះជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៧** .. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨** .. ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដូចមានចែងក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ។

**មាត្រា៩ -** ការប្រកាសមូលទោស

បទប្បញ្ញត្តិនៃមាត្រា៩៧ (ការប្រកាសមូលទោស) នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយ ចំពោះបទល្មើសដូចមានចែងក្នុងច្បាប់នេះ។ ការប្រកាសមូលទោសត្រូវអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មូលទោសចំពោះបទល្មើសទាំងឡាយដូចមានចែងក្នុងច្បាប់នេះ មិនអាចត្រូវបានជំនួសដោយទោសជំនួស ឬទោសបន្ថែមតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឡើយ។

**មាត្រា១០ -** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវបានគេរត់ពន្ធ

ជនត្រូវបានគេរត់ពន្ធ ពុំត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបញ្ញត្តិនៃច្បាប់នេះឡើយ ទោះបីជននោះបានប្រព្រឹត្តអំពើដែលពាក់ព័ន្ធនឹងការរត់ពន្ធមនុស្ស ដូចខាងក្រោម៖

១-ការចូលក្នុងប្រទេសមួយដោយខុសច្បាប់ ឬ

២-ការស្ថិតនៅក្នុងប្រទេសមួយដោយខុសច្បាប់ ឬ

៣-ការទទួល ការរក្សាទុក ឬការប្រើប្រាស់ឯកសារធ្វើដំណើរខុសច្បាប់ ឬឯកសារអត្តសញ្ញាណខុសច្បាប់ សម្រាប់គោលបំណងចូល ចេញ ឬស្នាក់នៅក្នុងប្រទេសមួយដោយខុសច្បាប់។

បញ្ញត្តិនេះមិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតចំពោះជនត្រូវបានគេរត់ពន្ធនោះទេ។

**មាត្រា១១ -** ការលើកលែងឱ្យរួចផុតពីទោស និងស្ថានសម្រាលទោស

បុគ្គលណាដែលបានចូលរួមប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងច្បាប់នេះ ត្រូវលើកលែងឱ្យរួចផុតពីការទទួលទោស ប្រសិនបើមុនការចោទប្រកាន់ បុគ្គលនោះបានបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ចអំពីអត្ថិភាពនៃអំពើនេះ ហើយបាននាំឱ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត។

ប៉ុន្តែ បុគ្គលនោះត្រូវទទួលបាននូវស្ថានសម្រាលទោស ប្រសិនបើការបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ចខាងលើ ធ្វើឡើងក្រោយការចោទប្រកាន់។ អានុភាពនៃស្ថានសម្រាលទោសនេះ ត្រូវអនុវត្តស្របតាមក្រមព្រហ្មទណ្ឌ។

## ជំពូកទី៣
## កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ទាក់ទងនឹងបទល្មើសរត់ពន្ធមនុស្ស

**មាត្រា១២ -** កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការជាមួយរដ្ឋបរទេសទាក់ទងនឹងបត្យាប័ន និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ជាអាទិ៍ ការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើស រួមទាំងការប្រមូល និងចែករំលែកព័ត៌មាន ការកំណត់អត្តសញ្ញាណបុគ្គល ការកំណត់អត្តសញ្ញាណទ្រព្យ ការឃាត់ទុកឬបង្កកទ្រព្យ និងការប្រមូលត្រឡប់មកវិញនូវផលនៃបទល្មើសពាក់ព័ន្ធនឹងការរត់ពន្ធមនុស្ស ត្រូវអនុវត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលកម្ពុជាជារដ្ឋភាគី។

# ជំពូកទី៤
# អវសានប្បញ្ញត្តិ

**មាត្រា១៣.-** ការប្រកាសឱ្យប្រើច្បាប់ និងការអនុវត្តច្បាប់

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះមានអានុភាពអនុវត្តភ្លាម។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.........ខែ..........ឆ្នាំ..........
នាសម័យប្រជុំរដ្ឋសភាលើកទី.............. នីតិកាលទី៧។
ថ្ងៃ...............ខែ...........ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ............

**ប្រធានរដ្ឋសភា**

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី**